# អនុសញ្ញា

# ស្តីពី

# ការបំបាត់រាល់ទំរង់នៃ
# ការរើសអើងប្រឆាំងនឹងនារីភេទ

# Convention on the Elimination of All Forms of Discrimination against Women

# អនុសញ្ញាស្តីអំពីការកំចាត់នូវ
# ការរើសអើងទាំងឡាយគ្រប់រូបភាពចំពោះស្ត្រី

ដោយហេតុថា អនុសញ្ញាស្តីអំពីការកំចាត់នូវការរើសអើងទាំងឡាយគ្រប់រូបភាពចំពោះស្ត្រីដែលមហាសន្និបាត អង្គការសហប្រជាជាតិបានអនុម័ត ថ្ងៃ ១៨ ធ្នូ ១៩៧៩

**អាស្រ័យហេតុនេះ** យើងខ្ញុំដែលជាសមាជិកនៃក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៃកម្ពុជា ប្រកាសថា ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ដោយបានពិនិត្យអនុសញ្ញាខាងលើនេះ និងចូលជាសមាជិក ហើយសន្យាថា នឹងគោរពព្រមទាំងអនុវត្តយ៉ាងទៀតទាត់នូវបទបញ្ញត្តិដែលមានចែងនៅក្នុងនោះ ។

**ដើម្បីជាសក្ខីភាពនៃកិច្ចសន្យានេះ** យើងខ្ញុំបានចុះហត្ថលេខាលើឧបករណ៍នៃការចូលជាសមាជិកនៅមហាប្រាសាទខេមរិន្ទ ភ្នំពេញ កម្ពុជា នៅថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩២ ។

សម្តេចព្រះនរោត្តម សីហនុ

---

## <u>កំណត់បន្ថែម</u>

អនុសញ្ញាស្តីពីការបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទ ដែលប្រទេសកម្ពុជាយើងបានចុះហត្ថលេខាចូលជាសមាជិកនៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩២ នៅក្នុងសម័យអន្តរកាលដោយ ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ហើយមិនបានផ្ញើអនុសញ្ញានេះ ឱ្យរាជរដ្ឋាភិបាលដើម្បីចុះផ្សាយក្នុងរាជកិច្ចឡើយ។

បច្ចុប្បន្នរាជរដ្ឋាភិបាលបានអនុញ្ញាត ឱ្យយកអនុសញ្ញាស្តីពីការបំបាត់រាល់ទំរង់នៃការរើសអើងនារីភេទនេះ មកចុះផ្សាយក្នុងរាជកិច្ច ដើម្បីឱ្យមានសុពលភាពក្នុងការប្រើប្រាស់ស្របតាមរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា។

# អនុសញ្ញាស្តីពីការបំបាត់រាល់ទំរង់នៃការរើសអើង ប្រឆាំងនឹងនារីភេទ

*បានអនុម័ត និងបើកចំហសំរាប់ចុះហត្ថលេខា ឱ្យសច្ចាប័ន និងចូលរួមដោយ សេចក្តីសំរេចចិត្តរបស់មហាសន្និបាតអង្គការសហប្រជាជាតិ លេខ៣៤/១៨០ នាថ្ងៃទី១៨ធ្នូ១៩៧៩ ។*

ចូលជាធរមាននៅថ្ងៃទី៣កញ្ញា១៩៨១ អនុលោមតាមមាត្រា២៧(១) ។

*រដ្ឋទាំងឡាយដែលជាភាគីនៃអនុសញ្ញានេះ...*

**ដោយកត់សំគាល់ឃើញថា** ធម្មនុញ្ញនៃអង្គការសហប្រជាជាតិ បានអះអាងជាថ្មីម្តងទៀត នូវការជឿជាក់ទៅលើសិទ្ធិមនុស្សជាមូលដ្ឋាន ទៅលើភាពថ្លៃថ្នូរ និងតម្លៃរបស់មនុស្ស ហើយនិងទៅលើសិទ្ធិស្មើគ្នារវាង បុរស និងនារី ...

**ដោយកត់សំគាល់ឃើញថា** សេចក្តីថ្លែងការណ៍ជាសាកលស្តីអំពីសិទ្ធិមនុស្ស បានអះអាងពីគោលការណ៍ស្តីអំពីការមិនអាចទទួលបាននូវការរើសអើង និងបានប្រកាសថា មនុស្សទាំងអស់កើតឡើងមានសេរីភាព និងមានសមភាពនៅក្នុងសេចក្តីថ្លៃថ្នូរ និងប្រកបដោយសិទ្ធិនានា ហើយថាមនុស្សគ្រប់រូបត្រូវតែមានសិទ្ធិ និងសេរីភាពទាំងឡាយ ដែល

មានចែងនៅក្នុងនោះ ដោយគ្មានការបែងចែកអ្វីទាំងអស់ រួមទាំងការបែងចែកភេទផង ...

**ដោយកត់សំគាល់ឃើញថា** រដ្ឋទាំងឡាយដែលជាភាគីនៃកតិកាសញ្ញា(កិច្ចព្រមព្រៀង)អន្តរជាតិស្តីពីសិទ្ធិមនុស្ស សុទ្ធតែមានកាតព្វកិច្ចក្នុងការធានាឲ្យបុរស និងនារីមានសិទ្ធិស្មើគ្នាក្នុងវិស័យសេដ្ឋកិច្ច សង្គម វប្បធម៌ ពលរដ្ឋ និងនយោបាយ...

**ដោយសង្កេតឃើញថា** អនុសញ្ញាអន្តរជាតិទាំងឡាយដែលត្រូវបានសម្រេចឡើងក្រោមកិច្ចឧបត្ថម្ភរបស់អង្គការសហប្រជាជាតិ និងអង្គការឯកទេសនានា រមែងតែងជំរុញសិទ្ធិស្មើភាពរវាងបុរស និងនារី ...

**ដោយកត់សំគាល់ឃើញផងដែរថា** សេចក្តីសម្រេចចិត្ត សេចក្តីថ្លែងការណ៍ និងការណែនាំទាំងឡាយ ដែលត្រូវបានអនុម័តឡើងដោយអង្គការសហប្រជាជាតិ និងអង្គការឯកទេសនានា រមែងតែងជំរុញនូវសិទ្ធិស្មើភាពរវាងបុរស និងនារី...

**ដោយមានកង្វល់ថា** ថ្វីដ្បិតតែមានឯកសារទាំងនេះហើយក្តី ក៏ការរើសអើងប្រឆាំងនឹងនារីភេទជាទូទៅនៅតែមាននៅឡើយ ...

**ដោយរំលឹកឡើងវិញថា** ការរើសអើងប្រឆាំងនឹងនារីភេទគឺជាការរំលោភទៅលើគោលការណ៍ នៃសិទ្ធិស្មើភាពគ្នា និងគោលការណ៍ស្តីអំពីការគោរពចំពោះភាពថ្លៃថ្នូរបស់មនុស្ស, គឺជាឧបសគ្គដល់ការចូលរួមរបស់នារី ក្នុងឋានៈស្មើភាពនឹងបុរស នៅក្នុងជីវភាពនយោបាយ សង្គម សេដ្ឋកិច្ច និងវប្បធម៌ នៅក្នុងប្រទេសរបស់ខ្លួន, គឺជាការប៉ះពាល់ដល់ការលូតលាស់នៃភាពសំបូររុងរឿងរបស់សង្គម និងរបស់គ្រួសារ

.....ធ្វើឲ្យកាន់តែមានការលំបាកដល់កិច្ចអភិវឌ្ឍន៍ដ៏ពេញលេញនៃសក្តានុពលភាព(potentialities) របស់នារី នៅក្នុងការបំរើប្រទេសរបស់ខ្លួន និងមនុស្សជាតិ ...

**ដោយមានកង្វល់ថា** នៅក្នុងភាពក្រីក្រលំបាក នារីភេទមានលទ្ធភាពតិចជាងគេបំផុត ក្នុងការស្វះស្វែងរកម្ហូបអាហារ សុខាភិបាល ការរៀនសូត្រ ការបណ្តុះបណ្តាលវិជ្ជាជីវៈ ហើយនិងលទ្ធភាពតិចជាងគេក្នុងការស្វះស្វែងរកការងារធ្វើ ក៏ដូចជាសេចក្តីត្រូវការផ្សេងៗទៀតផងដែរ...

**ដោយជឿជាក់ថា** ការចាត់តាំងឲ្យមានរបៀបរៀបរយសេដ្ឋកិច្ចអន្តរជាតិថ្មីមួយ ដែលឈរលើមូលដ្ឋានស្មើភាព និងយុត្តិធម៌ និងជាជំនួយយ៉ាងសំខាន់ ដល់ការជំរុញសមភាពរវាងបុរស និង នារី ..

**ដោយគូសបញ្ជាក់ថា** ការលុបបំបាត់នូវរបប*អាប៉ារថេត* (គឺរបបគ្រប់គ្រងដែលប្រកាន់ពណ៌សំបុរនៅប្រទេសអាហ្វ្រិកខាងត្បូង) រាល់ទំរង់នៃពូជសាសន៍និយម ការរើសអើងពូជសាសន៍ អាណានិគមនិយម អាណានិគមនិយមបែបថ្មី ការឈ្លានពាន ការកាន់កាប់ ការត្រួតត្រាពីសំណាក់បរទេស និងការលូកដៃរបស់បរទេសទៅក្នុងកិច្ចការផ្ទៃក្នុងរបស់រដ្ឋទាំងឡាយ គឺជាការចាំបាច់ក្នុងការធ្វើឲ្យសិទ្ធិបុរស និងនារីមានឡើងយ៉ាងពេញលេញ...

**ដោយអះអាងថា** ការពង្រឹងសន្តិភាព និងសន្តិសុខអន្តរជាតិ ការបន្ថយភាពតានតឹងអន្តរជាតិ កិច្ចសហប្រតិបត្តិការទៅវិញទៅមករវាងរដ្ឋទាំងឡាយ ដោយមិនគិតពីប្រព័ន្ធសេដ្ឋកិច្ច និងសង្គម ការរំ

សាយសព្វាវុធជាទូទៅ និងទាំងស្រុង ជាពិសេស គឺការរំសាយអាវុធនុយក្លេអ៊ែ ក្រោមការត្រួតពិនិត្យអន្តរជាតិយ៉ាងម៉ត់ចត់ និងដោយមានប្រសិទ្ធភាព, ការបញ្ជាក់ពីគោលការណ៍យុត្តិធម៌ សមភាព និងអំពីការផ្តល់ប្រយោជន៍ឲ្យគ្នាទៅវិញទៅមកក្នុងការទាក់ទងគ្នារវាងប្រទេសនានា ហើយនឹងការធ្វើឲ្យចេញជារូបរាង នូវសិទ្ធិស្វ័យសម្រេច និងសិទ្ធិបានឯករាជ្យរបស់ប្រជាជនដែលស្ថិតនៅក្រោមការត្រួតត្រារបស់បរទេស និងអាណានិគមនិយម ហើយនឹងក្រោមការកាន់កាប់របស់បរទេស ព្រមទាំងការគោរពអធិបតេយ្យជាតិ និងបូរណភាពទឹកដី នឹងជម្រុញឲ្យមានវឌ្ឍនភាព និងកិច្ចអភិវឌ្ឍន៍សង្គម ហើយលទ្ធផលដែលចេញពីនេះនឹងអាចរួមចំណែកក្នុងការធ្វើឲ្យមានភាពស្មើគ្នា យ៉ាងពេញលេញ រវាងបុរស និងនារី...

**ដោយជឿជាក់ថា** កិច្ចអភិវឌ្ឍន៍យ៉ាងពេញលេញនិងទាំងស្រុងរបស់ប្រទេសជាតិ សុខុមាលភាពពិភពលោក និងបុព្វហេតុសន្តិភាព ទាមទារឲ្យមានការចូលរួមជាអតិបរមារបស់នារី នៅក្នុងគ្រប់វិស័យ លើមូលដ្ឋានស្មើភាពគ្នានឹងបុរស...

**ដោយចងចាំនៅក្នុងចិត្ត** នូវការរួមចំណែកយ៉ាងធំធេងរបស់នារីនៅក្នុងសុខុមាលភាពរបស់គ្រួសារ និងក្នុងអភិវឌ្ឍន៍សង្គម ដែលសព្វថ្ងៃនេះមិនសូវមានការទទួលស្គាល់ឲ្យបានពេញលេញ, ដោយចងចាំនូវសារៈសំខាន់នៃមាតុភាពនៅក្នុងសង្គម ហើយនឹងតួនាទីជាឪពុកម្តាយនៅក្នុងគ្រួសារ និងនៅក្នុងការចិញ្ចឹមបីបាច់កូនចៅ ហើយនឹងដោយចាំជាប់ថា តួនាទីរបស់នារីក្នុងការបង្កើតកូនចៅមិនមែនជាមូលដ្ឋាននៃការ

រើសអើងទេនោះ ប៉ុន្តែ ការចិញ្ចឹមបីបាច់កូនចៅទាមទារឲ្យមានការរំលែកភារកិច្ចទទួលខុសត្រូវរវាងបុរស និងនារី និងសង្គមជារួម...

**ដោយដឹងច្បាស់ថា** ការប្រែប្រួលមុខនាទីជាប្រពៃណីរបស់បុរស ក៏ដូចជារបស់នារីនៅក្នុងសង្គម និងនៅក្នុងគ្រួសារ គឺជាការចាំបាច់ដើម្បីធ្វើឲ្យបានសំរេចនូវសមភាពយ៉ាងពេញលេញរវាងបុរស និងនារី...

**ដោយប្ដេជ្ញា**អនុវត្តនូវគោលការណ៍ទាំងឡាយ ដែលមានចែងនៅក្នុងសេចក្ដីថ្លែងការណ៍ស្ដីអំពីការបំបាត់ការរើសអើងប្រឆាំងនឹងនារីភេទ ហើយក្នុងទិសដៅនេះ នឹងអនុម័តរាល់វិធានការចាំបាច់នានា ដើម្បីបំបាត់ចោលការរើសអើងបែបនេះ នៅក្នុងគ្រប់ទំរង់ និងគ្រប់រូបភាព (របស់វា)...

**បានឯកភាពគ្នា**ដូចខាងក្រោមនេះ ÷

## ភាគ ១

### *មាត្រា១*

ដើម្បីបំរើគោលដៅនៃអនុសញ្ញានេះ ពាក្យថា«**ការរើសអើងប្រឆាំងនារីភេទ**» មានន័យថាការបែងចែក ការផាត់ចេញ ឬការកំហិតណាដែលធ្វើឡើងលើមូលដ្ឋានភេទ ហើយដែលបង្កឡើង ឬដែលមានទិសដៅធ្វើឲ្យខូចខាត ឬធ្វើឲ្យទៅជាមោឃៈដល់ការទទួលស្គាល់ ការទទួលបាន ឬការប្រើប្រាស់ដោយនារីភេទនូវសិទ្ធិមនុស្ស និងរាល់សេរី

ភាពជាគ្រឹះនៅក្នុងវិស័យនយោបាយ សេដ្ឋកិច្ច វប្បធម៌ ពលរដ្ឋ ឬក៏ក្នុងវិស័យផ្សេងៗទៀត លើមូលដ្ឋានស្មើភាពគ្នារវាងបុរស និងនារី ទោះជាក្នុងស្ថានភាពអាពាហ៍ពិពាហ៍បែបណាក៏ដោយ ។

## មាត្រា ២

រដ្ឋជាភាគីទាំងឡាយថ្កោលទោសការរើសអើងប្រឆាំងនារីភេទគ្រប់បែបគ្រប់យ៉ាងទាំងអស់ និងឯកភាពអនុវត្តតាមគ្រប់មធ្យោបាយដែលសមស្រប និងដោយឥតបង្អែបង្អង់ នូវគោលនយោបាយបំបាត់ចោលការរើសអើងប្រឆាំងនារីភេទ ហើយក្នុងទិសដៅនេះបានសន្យាថានឹង ៖

**(ក)** បញ្ចូលគោលការណ៍ នៃសមភាពរវាងបុរស និងនារីទៅក្នុងរដ្ឋធម្មនុញ្ញ និងបញ្ញត្តិច្បាប់នានាឯទៀតដែលសមស្រប បើសិនជាគោលការណ៍នេះមិនទាន់បានត្រូវបញ្ចូលនៅឡើយទេនោះ ហើយនឹងធានាតាមរយៈច្បាប់ និងរាល់មធ្យោបាយនានាដែលសមស្របនូវការអនុវត្តន៍ដ៏ជាក់ស្តែងនូវគោលការណ៍នេះ;

**(ខ)** អនុម័តនូវបញ្ញត្តិច្បាប់ និងវិធានការផ្សេងៗទៀតដែលសមស្រប ដោយរួមទាំងការដាក់ទណ្ឌកម្មផង បើសិនជាចាំបាច់ ដើម្បីហាមប្រាមមិនឲ្យមានការរើសអើងប្រឆាំងនារីភេទគ្រប់បែបទាំងអស់;

**(គ)** រៀបចំឲ្យមានកិច្ចគាំពារតាមផ្លូវច្បាប់ នូវសិទ្ធិរបស់នារីភេទឲ្យមានភាពស្មើគ្នានឹងបុរស ហើយនឹងធានានូវកិច្ចគាំពារដ៏មាន

ប្រសិទ្ធិភាព ចំពោះនារីភេទ តាមរយៈតុលាការជាតិ និងរាល់ស្ថាប័នសាធារណៈផ្សេងៗដែលមានសមត្ថកិច្ច ដើម្បីប្រឆាំងនឹងអំពើរើសអើងទាំងអស់;

(ឃ) តមមិនប្រព្រឹត្តនូវអំពើ ឬមានសកម្មភាពរើសអើងប្រឆាំងនារីភេទឡើយ ហើយនឹងត្រួតពិនិត្យឲ្យបានប្រាកដថា អាជ្ញាធរ និងស្ថាប័នសាធារណៈទាំងឡាយ នឹងធ្វើសកម្មភាពស្របទៅតាមកាតព្វកិច្ចនេះ;

(ង) ប្រកាន់យកនូវរាល់វិធានការសមស្របទាំងអស់ ដើម្បីបំបាត់ចោលរាល់ការរើសអើងប្រឆាំងនារីភេទ ដែលបានធ្វើឡើងដោយបុគ្គល ដោយអង្គការ ឬដោយសហគ្រាសណាមួយក្ដី;

(ច) ប្រកាន់យកវិធានការសមស្រប រួមទាំងបញ្ញត្តិច្បាប់ផង ដើម្បីផ្លាស់ប្ដូរ ឬលុបចោលនូវច្បាប់ បទបញ្ញត្តិ ទំលាប់ និងការអនុវត្តន៍ទាំងឡាយណា ដែលមានការរើសអើងប្រឆាំងនារីភេទ;

(ឆ) លុបចោលនូវបញ្ញត្តិព្រហ្មទណ្ឌនានារបស់ជាតិ ដែលមានការរើសអើងប្រឆាំងនារីភេទ ។

## មាត្រា ៣

នៅក្នុងគ្រប់វិស័យ ជាពិសេសនៅក្នុងវិស័យនយោបាយ សង្គម សេដ្ឋកិច្ច និងវប្បធម៌ រដ្ឋជាភាគីទាំងឡាយត្រូវប្រកាន់យកវិធានការដ៏សមស្របនានា រួមទាំងបញ្ញត្តិច្បាប់ផងដែរ ដើម្បីធ្វើឲ្យមានការចំរើនលូតលាស់ និងជឿនលឿនយ៉ាងពេញលេញរបស់នារីភេទ ក្នុងគោលដៅធា

នាំឲ្យនារីអាចប្រើប្រាស់ និងទទួលបាននូវសិទ្ធិ ព្រមទាំងសេរីភាពជាគ្រឹះទាំងឡាយ លើមូលដ្ឋានស្មើភាពនឹងបុរស ។

## មាត្រា៤

១. វិធានការពិសេសជាបណ្ដោះអាសន្ន ដែលរដ្ឋជាភាគីទាំងឡាយបានប្រកាន់យក ដើម្បីពន្លឿននូវសមភាពដ៏ជាក់ស្ដែងរវាងបុរស និងនារី មិនត្រូវបានចាត់ទុកថាជាការរើសអើង ដូចបានកំណត់នៅក្នុងអនុសញ្ញានេះទេ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏វិធានការទាំងនេះមិនត្រូវបង្កឲ្យមានការរក្សាទុកនូវស្តង់ដារមិនស្មើភាព ឬស្តង់ដារពីរដោយឡែកពីគ្នាឡើយ ។ វិធានការអស់ទាំងនេះនឹងត្រូវបញ្ឈប់នៅពេលណាដែលគោលដៅធ្វើឲ្យមានភាពស្មើគ្នា(រវាងបុរស និងនារី)ក្នុងវិស័យរាប់រកនិងវិស័យបំពេញវិជ្ជាជីវៈត្រូវបានសំរេចហើយ ។

២. រាល់វិធានការពិសេសទាំងឡាយ រាប់ទាំងវិធានការនានាដែលមានចែងក្នុងអនុសញ្ញានេះផង ដែលត្រូវបានរដ្ឋជាភាគីទាំងឡាយប្រកាន់យក ក្នុងគោលដៅគាំពារមាតុភាពនោះ មិនត្រូវចាត់ទុកថាជាការរើសអើងឡើយ ។

## មាត្រា៥

រដ្ឋជាភាគីទាំងឡាយ នឹងប្រកាន់យករាល់វិធានការដែលសមស្រប ៖

**(ក)** ដើម្បីកែប្រែទំរង់ឥរិយាបថបុរស និងនារី ខាងវិស័យសង្គម និងវប្បធម៌ ក្នុងទស្សនៈបំបាត់ចោលនូវការប្រកែប្រកាន់ និងការអនុវត្តន៍តាមទំលាប់ ព្រមទាំងការអនុវត្តន៍ផ្សេងទៀត ដែលឈរលើមូលដ្ឋាននៃការគិតអំពីភាពអន់ថយ ឬឧត្តមភាពរបស់ភេទណាមួយ ឬគិតអំពីតួនាទីជាទំលាប់របស់បុរស និងនារី;

**(ខ)** ដើម្បីធានាថា ក្នុងការអប់រំគ្រួសារ ត្រូវរួមបញ្ចូលទាំងការយល់ដឹងដ៏ត្រឹមត្រូវមួយ ដែលចាត់ទុកមាតុភាពថាជាមុខការសង្គមមួយ ហើយនឹងការទទួលស្គាល់ដល់ភារកិច្ចរួមរបស់បុរស និងនារី នៅក្នុងការចិញ្ចឹមបីបាច់ និងការចំរើនលូតលាស់របស់កូនចៅខ្លួន ដោយត្រូវឲ្យយល់ថា នៅក្នុងករណីណាក៏ដោយ ផលប្រយោជន៍របស់កុមារ គឺជាផលប្រយោជន៍ដ៏ចំបងបង្អស់ ។

## មាត្រា ៦

រដ្ឋជាភាគីនឹងប្រកាន់យកវិធានការសមស្របទាំងអស់ រួមទាំងបញ្ញត្តិច្បាប់ផង ដើម្បីលុបបំបាត់រាល់ទំរង់នៃការជួញដូរនារី និងអាជីវកម្មផ្នែកពេស្យាកម្មនារីភេទ ។

## ភាគ ២

### មាត្រា ៧

រដ្ឋជាភាគីត្រូវប្រកាន់យកវិធានការសមស្របទាំងអស់ ដើម្បីបំបាត់ការរើសអើងប្រឆាំងនឹងនារីភេទ នៅក្នុងជីវភាពនយោបាយ និងក្នុងជីវភាពសាធារណៈនៃប្រទេសជាតិ ហើយជាពិសេស ត្រូវធានាជូននារីភេទ ដោយឈរលើមូលដ្ឋានស្មើភាពនឹងបុរស នូវសិទ្ធិ (ទាំងឡាយដូចខាងក្រោមនេះ) ÷

**(ក)** សិទ្ធិបោះឆ្នោតនៅក្នុងរាល់ពេលបោះឆ្នោត និងបោះឆ្នោតនៅរាល់ពេលមានប្រជាមតិទាំងអស់ ហើយនិងសិទ្ធិឈរឈ្មោះបោះឆ្នោតសំរាប់ស្ថាប័នគ្រប់ជាន់ថ្នាក់ ដែលត្រូវជ្រើសតាំងដោយការបោះឆ្នោតជាសាធារណៈ ;

**(ខ)** សិទ្ធិចូលរួមនៅក្នុងការគាក់តែងគោលនយោបាយរបស់រដ្ឋាភិបាល ហើយនឹងចូលរួមក្នុងការអនុវត្តន៍គោលនយោបាយនេះ ព្រមទាំងសិទ្ធិទទួលដំណែង និងបំពេញមុខងារសាធារណៈនៅក្នុងរដ្ឋាភិបាលគ្រប់ជាន់ថ្នាក់ ;

**(គ)** សិទ្ធិចូលរួមនៅក្នុងអង្គការមិនមែនរដ្ឋាភិបាល និងសមាគមនានាដែលទាក់ទិនទៅនឹងជីវភាពសាធារណៈ និងជីវភាពនយោបាយរបស់ប្រទេសជាតិ ។

## មាត្រា ៨

រដ្ឋជាភាគីនឹងប្រកាន់យកនូវរាល់វិធានការសមស្របនានា ដើម្បីធានាឲ្យនារីអាចមានឱកាសចូលរួម ដោយស្មើភាពនឹងបុរស និងដោយគ្មានការរើសអើងអ្វីទាំងអស់ ក្នុងការតំណាងរដ្ឋាភិបាលរបស់ខ្លួននៅក្នុងថ្នាក់អន្តរជាតិ ហើយនឹងចូលរួមនៅក្នុងការងាររបស់អង្គការអន្តរជាតិទាំងឡាយ ។

## មាត្រា ៩

១. រដ្ឋជាភាគីទាំងឡាយត្រូវផ្តល់ជូននារី នូវសិទ្ធិស្មើភាពនឹងបុរស ក្នុងការផ្លាស់ប្តូរសញ្ជាតិ ឬរក្សាសញ្ជាតិរបស់ខ្លួន ។ រដ្ឋនឹងធានាជាពិសេសថា ការរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេស ឬការផ្លាស់ប្តូរសញ្ជាតិរបស់ប្តី នឹងមិនបណ្តាលឲ្យប្រពន្ធផ្លាស់ប្តូរសញ្ជាតិជាស្វ័យប្រវត្តិ ឬធ្វើឲ្យប្រពន្ធគ្មានសញ្ជាតិ ឬក៏បង្ខំឲ្យប្រព័ន្ធត្រូវតែប្រកាន់យកសញ្ជាតិរបស់ប្តីឡើយ ។

២. រដ្ឋជាភាគីទាំងឡាយ នឹងផ្តល់ជូននារីនូវសិទ្ធិស្មើភាពនឹងបុរសក្នុងបញ្ហាសញ្ជាតិរបស់កូនចៅខ្លួនផងដែរ ។

## ភាគ ៣

### មាត្រា ១០

រដ្ឋជាភាគីទាំងឡាយត្រូវប្រកាន់យកនូវវិធានការសមស្របទាំងអស់ ដើម្បីបំបាត់ការរើសអើងប្រឆាំងនារីភេទ ដើម្បីធានាជូននារីភេទនូវសិទ្ធិស្មើភាពនឹងបុរស នៅក្នុងវិស័យអប់រំ និងជាពិសេសដោយឈរលើមូលដ្ឋានសមភាពរវាងបុរស និងនារីដើម្បីធានា ៖

**(ក)**ល័ក្ខខ័ណ្ឌដូចគ្នាក្នុងការទទួលសេចក្ដីណែនាំខាងមុខរបរ និងខាងវិជ្ជាជីវៈ ព្រមទាំងល័ក្ខខ័ណ្ឌដូចគ្នាក្នុងការចូលរៀន និងការទទួលសញ្ញាប័ត្រនៅក្នុងគ្រឹះស្ថានសិក្សាគ្រប់ផ្នែក ទាំងនៅជនបទ ទាំងនៅទីក្រុង។ សមភាពនេះត្រូវតែធានាឲ្យមាននៅក្នុងការអប់រំកំរិតមត្តេយ្យ ចំណេះទូទៅ តិចនិច វិជ្ជាជីវៈ និងការសិក្សាតិចនិចជាន់ខ្ពស់ ក៏ដូចជានៅក្នុងការហ្វឹកហ្វឺនវិជ្ជាជីវៈគ្រប់ផ្នែកផងដែរ ;

**(ខ)** ឲ្យមានមុខវិជ្ជាដូចគ្នា ការប្រឡងដូចគ្នា បុគ្គលិកបង្រៀនប្រកបដោយគុណសម្បត្តិដូចគ្នា គ្រឹះស្ថានសិក្សា ហើយនិងសម្ភារៈសិក្សាក្នុងគុណភាពដូចគ្នា ;

**(គ)** ការបំបាត់នូវទស្សនៈជាទំលាប់ស្ដីពីតួនាទីរបស់បុរស និងនារីនៅគ្រប់កំរិត និងនៅក្នុងគ្រប់ទំរង់នៃការអប់រំរៀនសូត្រ តាមរយៈការជម្រុញឲ្យមានការសិក្សារួមគ្នា និងប្រភេទអប់រំផ្សេងៗទៀតដែលនឹងជួយធ្វើឲ្យសំរេចទិសដៅនេះ ហើយជាពិសេស តាមរយៈការរៀនសារឡើង

វិញនូវអត្ថបទសិក្សា កម្មវិធីសិក្សា ហើយនិងការសំរបវិធីបង្រៀន ;

**(ឃ)** លទ្ធភាពដូចគ្នានៅក្នុងការទទួលបានអាហារូបករណ៍ ឬការទទួលបាននូវជំនួយឧបត្ថម្ភផ្សេងៗសំរាប់ការសិក្សា ;

**(ង)** លទ្ធភាពដូចគ្នាក្នុងការទទួលបាននូវ កម្មវិធីរៀនសូត្រដែលអាចបន្តទៅថ្នាក់លើ រួមទាំងកម្មវិធីអក្ខរកម្មសំរាប់មនុស្សពេញវ័យ និងសំរាប់វិជ្ជាជីវៈ ជាពិសេសគឺកម្មវិធីដែលមានទិសដៅបន្ថយគំលាតរវាងបុរស និងនារី ចាប់តាំងពីដើមទីបំផុតនៅក្នុងការអប់រំរៀនសូត្រ ;

**(ច)** បន្ថយអត្រាសិស្សនារី ដែលបោះបង់ការសិក្សា និងការចាត់តាំងកម្មវិធីសិក្សាសំរាប់យុវនារី និងនារីទាំងឡាយដែលបានបោះបង់ការសិក្សារហ័សពេក ;

**(ឆ)** លទ្ធភាពដូចគ្នាក្នុងការចូលរួមយ៉ាងសកម្មក្នុងកីឡា និងកាយសិក្សា ;

**(ជ)** ការទទួលបាននូវពត៌មានស្តីពីការអប់រំនៅលើផ្នែកនិមួយៗដើម្បីជួយធានាដល់សុខភាព និងសុខុមាលភាពរបស់គ្រួសារ ដោយរួមបញ្ចូលទាំងពត៌មាន និងដំបូន្មានស្តីពីផែនការគ្រួសារផង ។

## មាត្រា ១១

**១.** រដ្ឋជាភាគីទាំងឡាយ នឹងប្រកាន់យករាល់វិធានការសមស្របនានា ដើម្បីបំបាត់ការរើសអើងប្រឆាំងនារីភេទនៅលើវិស័យបំពេញការ

ងារ ដើម្បីធានាសិទ្ធិស្មើភាព ដែលឈរលើមូលដ្ឋានសមភាពរវាងបុរស និងនារី ជាពិសេស ៖

**(ក)** សិទ្ធិធ្វើការងារដែលជាសិទ្ធិផ្សារភ្ជាប់ទៅនឹងមនុស្សគ្រប់រូប ;

**(ខ)** សិទ្ធិមានលទ្ធភាពដូចគ្នាក្នុងការបំពេញការងារ រួមទាំងការអនុវត្តន៍លក្ខណៈវិនិច្ឆ័យជ្រើសរើសដូចគ្នានៅក្នុងការបំពេញការងារ ;

**(គ)** សិទ្ធិក្នុងការជ្រើសរើសដោយសេរីនូវមុខរបរ និងការងារ សិទ្ធិទទួលការតម្លើងតួនាទី សិទ្ធិដើម្បីមានស្ថិរភាពការងារ ហើយនឹង (សិទ្ធិដើម្បីទទួលបាន)រាល់អត្ថប្រយោជន៍ និងល័ក្ខខ័ណ្ឌនៃការងារ ព្រមទាំងសិទ្ធិក្នុងការទទួលបាននូវការបណ្តុះបណ្តាលវិជ្ជាជីវៈ វិក្រឹតការ រួមបញ្ចូលទាំងកម្មសិក្សា ការបណ្តុះបណ្តាលវិជ្ជាជីវៈកំរិតខ្ពស់ និងការហ្វឹកហ្វឺនមុខវិជ្ជាផ្សេងៗទៀតដែលតែងតែមានជារឿយៗផង ;

**(ឃ)** សិទ្ធិក្នុងការទទួលប្រាក់បំណាច់ស្មើគ្នារួមទាំងអត្ថប្រយោជន៍ទាំងឡាយផង ហើយនឹងសិទ្ធិទទួលបៀវត្សស្មើគ្នាចំពោះការងារស្មើគ្នា ក៏ដូចជាសិទ្ធិទទួលការទុកដាក់ស្មើគ្នា នៅក្នុងការវាយតម្លៃគុណភាពការងារដែរ ;

**(ង)** សិទ្ធិទទួលបានសន្តិសុខសង្គម ជាពិសេសនៅក្នុងករណីចូលនិវត្តន៍ បាត់អាជីព(អត់ការធ្វើ) មានជម្ងឺ ពិការភាព និងអាយុចំណាស់ ហើយនឹងការបាត់បង់សមត្ថភាពបំពេញពលកម្មផ្សេងៗទៀត ក៏ដូចជាសិទ្ធិសំរាកដោយបានទទួលប្រាក់បៀវត្សផងដែរ ;

**(ច)** សិទ្ធិទទួលបានកិច្ចគាំពារសុខភាព និងសិទ្ធិប្រកបដោយនិរភ័យ(ភាពគ្មានគ្រោះថ្នាក់)នៅក្នុងស្ថានភាពបំពេញការងារ រួមទាំងការធានា

សន្តិសុខក្នុងមុខការបង្កបង្កើតកូនចៅផងដែរ ។

**២.** ដើម្បីបង្ការកុំឲ្យមានការរើសអើងប្រឆាំងនារីភេទ លើមូលដ្ឋានអាពាហ៍ពិពាហ៍ ឬមាតុភាព ហើយនិងដើម្បីធានាសិទ្ធិបំពេញពលកម្មរបស់នារីឲ្យបានពិតប្រាកដនោះ រដ្ឋជាភាគីទាំងឡាយត្រូវប្រកាន់យកនូវវិធានការសមស្របទាំងឡាយដូចខាងក្រោមនេះ ÷

**(ក)** ហាមឃាត់មិនឲ្យបញ្ឈប់(នារី)ពីការងារដោយសារការមានផ្ទៃពោះ ឬការសំរាកក្នុងពេញសំរាលកូន និងហាមមិនឲ្យមានការរើសអើងក្នុងការបញ្ឈប់ពីការងារដោយយោងទៅលើស្ថានភាពអាពាហ៍ពិពាហ៍ ដោយមានដាក់ទណ្ឌកម្ម (ឬផាកពិន័យចំពោះអ្នកប្រព្រឹត្តបំពាន)ផង ;

**(ខ)** អនុញ្ញាតឲ្យមានការសំរាកក្នុងពេលសំរាលកូន ដោយបានទទួលប្រាក់បៀវត្ស ឬក៏បានទទួលអត្ថប្រយោជន៍សង្គមប្រហាក់ប្រហែលគ្នា ដោយមិនបាត់បង់ការងារដើម មិនបាត់បង់ភាពចាស់វស្សាក្នុងការងារ ឬប្រាក់ឧបត្ថម្ភសង្គមឡើយ ;

**(គ)** កម្លាឲ្យមានការផ្តត់ផ្គង់ផ្នែកគាំទ្រសង្គមកិច្ចជាចាំបាច់នានា ដើម្បីជួយឲ្យឪពុកម្តាយអាចគួបផ្សំភារពកិច្ចគ្រួសារជាមួយនិងការទទួលខុសត្រូវក្នុងការងារ និងការចូលរួមនៅក្នុងជីវភាពសាធារណៈ ជាពិសេសតាមការជំរុញនូវការបង្កើត និងការអភិវឌ្ឍន៍បណ្តាញថែទាំកុមារ ;

**(ឃ)** នៅក្នុងប្រភេទការងារណាដែលអាចប៉ះពាល់ដល់សុខភាពត្រូវផ្តល់នូវកិច្ចគាំពារជាពិសេសដល់នារីមានផ្ទៃពោះ ។

**៣.** បញ្ញត្តិច្បាប់គាំពារ ដែលទាក់ទិនទៅនឹងបញ្ហានានា ដែលបានលើកឡើងនៅក្នុងមាត្រានេះ នឹងត្រូវលើកយកមកពិនិត្យជាទៀង

ទាត់ ដោយផ្អែកទៅលើការចេះដឹងផ្នែកវិទ្យាសាស្ត្រ និងតិចណូឡូស៊ី ហើយត្រូវសើរើពិនិត្យសារឡើងវិញ លុបចោល ឬពន្យាពេលទៅតាមការចាំបាច់ ។

## មាត្រា ១២

១. រដ្ឋជាភាគីទាំងឡាយនឹងប្រកាន់យករាល់វិធានការសមស្រមទាំងឡាយ ដើម្បីបំបាត់ការរើសអើងប្រឆាំងនារីភេទ នៅក្នុងវិស័យសុខាភិបាល ដើម្បីធានាឲ្យមាននូវកិច្ចថែទាំសុខភាពចំពោះនារី ដោយឈរលើមូលដ្ឋានស្មើភាពនឹងបុរស ហើយដោយរាប់បញ្ចូលទាំងកិច្ចការដែលទាក់ទិនទៅនឹងផែនការគ្រួសារថែមទៀតផង ។

២. ក្រៅពីបញ្ញត្តិដែលបានចែងនៅក្នុងកថាខណ្ឌ១នៃមាត្រានេះ រដ្ឋជាភាគីទាំងឡាយបានធានាដល់នារីភេទនូវរាល់សេវាសមស្របទាំងអស់ ដែលទាក់ទិនទៅនឹងការពរពោះ ការសំរាលកូន ហើយនឹងរយៈពេលក្រោយសំរាលកូន ដោយឥតគិតថ្លៃបើសិនជាចាំបាច់ ព្រមទាំងផ្តល់នូវម្ហូបអាហារសមស្រប ក្នុងរយៈពេលពរពោះ និងពេលបំបៅកូនផងដែរ ។

## មាត្រា ១៣

រដ្ឋជាភាគីទាំងឡាយត្រូវប្រកាន់យករាល់វិធានការសមស្របនានា ដើម្បីបំបាត់ការរើសអើងប្រឆាំងនារីភេទ នៅក្នុងវិស័យផ្សេងទៀត

នៃជីវភាពសេដ្ឋកិច្ច និងសង្គម ដើម្បីធានា ដោយឈរលើមូលដ្ឋានស្មើភាពរវាងបុរស និងនារី នូវសិទ្ធិដូចគ្នាជាពិសេស ៖

**(ក)** សិទ្ធិទទួលបានអត្ថប្រយោជន៍គ្រួសារ;

**(ខ)** សិទ្ធិខ្ចីប្រាក់ពីធនាគារ បញ្ចាំ និងទទួលបានឥណទានហិរញ្ញវត្ថុក្នុងទម្រង់ផ្សេងៗទៀត;

**(គ)** សិទ្ធិចូលរួមក្នុងសកម្មភាពកំសាន្ត កីឡា និងរាល់ទិដ្ឋភាពនៃជីវភាពវប្បធម៌ទាំងឡាយ ។

## មាត្រា ១៤

**១.** រដ្ឋជាភាគីទាំងឡាយត្រូវគិតគូរដល់បញ្ហាជាពិសេសដែលនារីនៅជនបទត្រូវប្រឈមមុខ ហើយនឹងតួនាទីដ៏សំខាន់របស់នារីជនបទក្នុងការធ្វើឲ្យសេដ្ឋកិច្ចគ្រួសារខ្លួនមានការរស់រាន ដោយរួមទាំងការងាររបស់នារីទាំងនោះ នៅក្នុងវិស័យគ្មានចំណូលនៃសេដ្ឋកិច្ចទៀតផង ហើយ(រដ្ឋជាភាគីទាំងឡាយ)ត្រូវប្រកាន់យកនូវវិធានការសមស្របនានា ដើម្បីធានាឲ្យមានការអនុវត្តន៍តាមបញ្ញត្តិនៃអនុសញ្ញានេះចំពោះនារីនៅជនបទផង។

**២.** រដ្ឋជាភាគីទាំងឡាយនឹងប្រកាន់យកវិធានការសមស្របនានា ដើម្បីបំបាត់ការរើសអើងប្រឆាំងនារីនៅជនបទ ដើម្បីឲ្យអ្នកទាំងនោះអាចចូលរួម និងទទួលបាននូវអត្ថប្រយោជន៍ ពីកិច្ចអភិវឌ្ឍន៍ជនបទ ដោយឈរលើមូលដ្ឋានសមភាពរវាងបុរស និងនារី ហើយជាពិសេស (រដ្ឋជាភាគីទាំងឡាយ)ត្រូវធានាដល់នារីជនបទទាំងនោះ នូវសិទ្ធិ ៖

**(ក)** ចូលរួមក្នុងការតាក់តែង និងការអនុវត្តន៍ផែនការអភិវឌ្ឍន៍គ្រប់ជាន់ថ្នាក់;

**(ខ)** អាចទទួលបាននូវរាល់កិច្ចឧបត្ថម្ភផ្នែកសុខាភិបាល រួមទាំងការទទួលពត៌មាន ការជូនមតិ និងកិច្ចឧបត្ថម្ភនានានៅក្នុងផែនការគ្រួសារថែមទៀតផង;

**(គ)** ទទួលបានដោយផ្ទាល់នូវអត្ថប្រយោជន៍ ពីកម្មវិធីសន្តិសុខសង្គម;

**(ឃ)** ទទួលបាននូវការហ្វឹកហ្វឺន និងការអប់រំគ្រប់ប្រភេទ ទាំងរៀបរយ និងទាំងមិនរៀបរយ រួមទាំងការងារទាក់ទិនទៅនឹងអក្ខរកម្មផ្នែកវិជ្ជាជីវៈ និងក្រៅពីនេះ ការទទួលនូវអត្ថប្រយោជន៍ពីកិច្ចឧបត្ថម្ភ(សេវា)សហគមន៍ ព្រមទាំងកិច្ចឧបត្ថម្ភជាបន្ទាប់បន្សំដទៃទៀត ដើម្បីបង្កើនសមត្ថកិច្ចប៉ិនប្រសប់ខាងវិស័យតិចនិចរបស់ខ្លួន;

**(ង)** រៀបចំជាក្រុមជួយខ្លួនដោយខ្លួនឯង ហើយនឹងបង្កើតសហករណ៍ ដើម្បីឲ្យមានលទ្ធភាពស្មើគ្នាក្នុងការទទួលផលផ្នែកសេដ្ឋកិច្ច តាមរយៈការបំពេញការងារ ឬស្វ័យបំពេញការងារ(ការរកស៊ីដោយខ្លួនឯង);

**(ច)** ចូលរួមក្នុងរាល់សកម្មភាពរបស់សហគមន៍;

**(ឆ)** អាចទទួលបាននូវឥណទាន និងការខ្ចីបុលផ្នែក(ប្រស់រាប់ធ្វើ)កសិកម្ម ទទួលបាននូវមធ្យោបាយដោះស្រាយក្នុងការរកទីផ្សារ(ដើម្បីលក់ដូរភោគផល) និងតិចណូឡូស៊ីសមស្រប ហើយនឹងទទួលបាននូវស្ថានភាពស្មើគ្នានៅក្នុងការកែទំរង់ដីធ្លី និងការកែទំរង់កសិកម្ម ក៍ដូចជានៅក្នុងគំរោងបែងចែកដីធ្លីផងដែរ;

(ជ) រីករាយនឹងស្ថានភាពរស់នៅមួយដ៏សមរម្យ ជាពិសេសក្នុងចំណុចទាក់ទិនដល់បញ្ហាផ្ទះសំបែង អនាម័យ អគ្គិសនី និងការផ្គត់ផ្គង់ទឹក ការដឹកជញ្ជូន និងទាក់ទងពត៌មាន ។

# ភាគ ៤

## មាត្រា ១៥

១. នៅចំពោះមុខច្បាប់ រដ្ឋជាភាគីទាំងឡាយត្រូវផ្តល់ជូននារីនូវភាពស្មើគ្នានឹងបុរស ។

២. នៅក្នុងផ្នែករដ្ឋប្បវេណី រដ្ឋជាភាគីត្រូវផ្តល់ចំពោះនារីភេទនូវសមត្ថកិច្ចខាងផ្លូវច្បាប់ដូចគ្នានឹងបុរស ហើយត្រូវផ្តល់លទ្ធភាពស្មើគ្នាក្នុងការប្រើប្រាស់សមត្ថកិច្ចនេះ ។ ជាពិសេស រដ្ឋជាភាគីត្រូវផ្តល់ចំពោះនារីភេទនូវសិទ្ធិដូចគ្នា ក្នុងការចុះកិច្ចសន្យា និងក្នុងការគ្រប់គ្រងសម្បត្តិទ្រព្យ ហើយត្រូវចាត់ទុកពួកគេស្មើៗគ្នា នៅក្នុងគ្រប់ដំណាក់កាលនៃនីតិវិធីនៅក្នុងការជំនុំជំរះ និងនៅតុលាការ ។

## មាត្រា ១៦

១. រដ្ឋជាភាគីនឹងប្រកាន់យកគ្រប់វិធានការសមស្របទាំងអស់ដើម្បីបំបាត់ការរើសអើងប្រឆាំងនារីភេទ នៅក្នុងគ្រប់វិស័យ ដែលទាក់ទិនទៅនឹងអាពាហ៍ពិពាហ៍ និងទំនាក់ទំនងគ្រួសារ និងជាពិសេស ដោយឈរលើមូលដ្ឋានសមភាពរវាងបុរស និងនារី រដ្ឋត្រូវធានា(ជូននារី)នូវ ៖

**(ក)** សិទ្ធិដូចគ្នាក្នុងអាពាហ៍ពិពាហ៍;

**(ខ)** សិទ្ធិដូចគ្នាក្នុងការជ្រើសរើសគូស្រករដោយសេរី និងរៀបអាពាហ៍ពិពាហ៍ដោយការស្ម័គ្រចិត្តទាំងស្រុង និងដោយគ្មានការបង្ខិតបង្ខំ;

**(គ)** សិទ្ធិ និងការទទួលខុសត្រូវដូចគ្នានៅក្នុងចំណងអាពាហ៍ពិពាហ៍ និងនៅក្នុងការរំសាយកិច្ចអាពាហ៍ពិពាហ៍នេះ(ការលែងលះគ្នា);

**(ឃ)** សិទ្ធិ និងការទទួលខុសត្រូវដូចគ្នា នៅក្នុងតួនាទីជាឪពុកម្តាយ នៅលើគ្រប់វិស័យដែលទាក់ទិនទៅនឹងកូនចៅខ្លួន ដោយមិនគិតពីស្ថានភាពអាពាហ៍ពិពាហ៍ឡើយ, នៅក្នុងគ្រប់ករណីទាំងអស់ ផលប្រយោជន៍របស់កូនចៅត្រូវស្ថិតនៅជាចំបង ;

**(ង)** សិទ្ធិដូចគ្នាក្នុងការសម្រេចដោយសេរី និងក្នុងស្មារតីទទួលខុសត្រូវ នូវចំនួនកូន និងចន្លោះពេលដែលត្រូវមានកូន ហើយមានលទ្ធភាពនឹងទទួលពត៌មាន ការអប់រំ និងមធ្យោបាយនានា ដែលអាចឲ្យនារីប្រើប្រាស់បាននូវសិទ្ធិទាំងឡាយនេះ ;

(ច) សិទ្ធិ និងការទទួលខុសត្រូវដូចគ្នានៅក្នុងការថែទាំ (guardianship) ការធ្វើអាណាព្យាបាល (Wardship) ការទទួលបន្ទុក (trusteeships) និងការសុំចិញ្ចឹមកូន ឬក៏នៅក្នុងទម្រង់ដូចគ្នានេះ បើសិនជាគោលគំនិត (concept) ទាំងនេះមាននៅក្នុងបញ្ញត្តិច្បាប់ប្រទេសជាតិហើយ ។ នៅក្នុងគ្រប់ករណីទាំងអស់ ផលប្រយោជន៍របស់កូនចៅត្រូវស្ថិតនៅជាចំបង ;

**(ឆ)** សិទ្ធិជាបុគ្គលដូចគ្នាក្នុងតួនាទីជាប្តី និងប្រពន្ធ រួមបញ្ចូល

ទាំងការជ្រើសរើស នាមត្រកូល វិជ្ជាជីវៈ និងមុខរបរផង ;

(ជ) សិទ្ធិដូចគ្នាសំរាប់គូស្រករទាំងពីរ នៅក្នុងការកាន់កាប់កម្មសិទ្ធិ ការទទួលបាន ការចាត់ចែង ការគ្រប់គ្រង ការអាស្រ័យផល និងប្រើប្រាស់កម្មសិទ្ធិ ទោះជាដោយមិនគិតថ្លៃ ឬគិតថ្លៃក្តី ។

២. ការភ្ជាប់ពាក្យ និងការរៀបអាពាហ៍ពិពាហ៍បុត្រធីតាពុំមានឥទ្ធិពលអ្វីខាងផ្លូវច្បាប់សោះឡើយ ដូច្នេះត្រូវតែប្រកាន់យកវិធានការចាំបាច់នានា រួមបញ្ចូលទាំងបញ្ញត្តិច្បាប់ផង ដើម្បីកំណត់ពីអាយុតិចបំផុតក្នុងការរៀបអាពាហ៍ពិពាហ៍ ហើយនិងការដាក់កំហិតឲ្យចុះបញ្ជីការអាពាហ៍ពិពាហ៍ជាចាំបាច់នៅក្នុងបញ្ជីផ្លូវការ ។

## ភាគ ៥

## មាត្រា ១៧

១. ដើម្បីត្រួតពិនិត្យវឌ្ឍនភាពក្នុងការអនុវត្តន៍អនុសញ្ញានេះ ត្រូវរៀបចំឲ្យមានជាគណៈកម្មាធិការសំរាប់ទទួលបន្ទុកការលុបបំបាត់ការរើសអើងប្រឆាំងនឹងនារីភេទ (ចាប់ពីចំណុចនេះទៅនឹងប្រើតែត្រឹមពាក្យ**គណៈកម្មាធិការ**) ដែល នៅពេលអនុសញ្ញានេះចូលជាធរមាន នឹងមានសមាសភាព ១៨ រូប ហើយនៅពេលដែលរដ្ឋជាភាគីទី ៣៥ បានឲ្យសច្ចាប័ន ឬបានចូលរួមហើយ (គណៈកម្មាធិការនេះ)នឹងមានដល់ទៅ ២៣ រូប ដែលជាអ្នកឯកទេស ប្រកបដោយជំហរសីលធម៌ និងសមត្ថកិច្ចខ្ពស់ នៅក្នុងវិស័យដែលជាក្របខ័ណ្ឌនៃអនុសញ្ញានេះ ។ អ្នកឯកទេសទាំងនេះ នឹងត្រូវរដ្ឋជាភា

គឺបោះឆ្នោតជ្រើសតាំងឡើង ពីក្នុងចំណោមពលរដ្ឋរបស់ខ្លួន ហើយនឹងត្រូវបំពេញការងារ ក្នុងឋានៈផ្ទាល់ខ្លួន និងដោយយោលទៅលើការបែងចែកសមស្របតាមភូមិសាស្ត្រ និងតាមភាពជាតំណាងនៃទំរង់អារ្យធម៌ផ្សេងៗ ក៏ដូចជាទៅតាមប្រព័ន្ធច្បាប់សំខាន់ៗផងដែរ ។

២. សមាជិកទាំងឡាយនៃគណៈកម្មាធិការ នឹងត្រូវជ្រើសតាំងឡើងតាមរយៈការបោះឆ្នោតជាសំងាត់លើបញ្ជីរាយនាមមួយ ដែលស្នើឡើងដោយរដ្ឋជាភាគីទាំងឡាយ។ រដ្ឋជាភាគីនិមួយៗអាចស្នើបេក្ខជនបានម្នាក់ ក្នុងចំណោមពលរដ្ឋរបស់ខ្លួន ។

៣. ការបោះឆ្នោតជាលើកដំបូងបង្អស់នឹងត្រូវធ្វើឡើង ៦ខែ ក្រោយអនុសញ្ញានេះចូលជាធរមាន។ បីខែយ៉ាងតិចមុនពេលដល់កំណត់នៃការបោះឆ្នោតនិមួយៗ អគ្គលេខាធិការអង្គការសហប្រជាជាតិ នឹងធ្វើលិខិតដល់រដ្ឋជាភាគីទាំងឡាយ ស្នើសុំឲ្យឧទ្ទេសនាមបេក្ខជនរបស់ខ្លួន ក្នុងរយៈពេលពីរខែ។ អគ្គលេខាធិការនឹងរៀបចំបញ្ជីឈ្មោះបេក្ខជនតាមលំដាប់អក្សរ ដោយមានបញ្ជាក់ប្រាប់ពីរដ្ឋជាភាគីដែលឧទ្ទេសនាមផង ហើយនឹងបញ្ជូនបញ្ជីនេះទៅគ្រប់រដ្ឋជាភាគីទាំងឡាយ។

៤. ការបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មាធិការ នឹងត្រូវធ្វើឡើងក្នុងសម័យប្រជុំនៃរដ្ឋជាភាគីទាំងឡាយ ដែលត្រូវបានកោះឡើងដោយអគ្គលេខាធិការនៅទីស្នាក់ការអង្គការសហប្រជាជាតិ ។ នៅទីប្រជុំ ដែលទាមទារវត្តមានពីរភាគបីនៃរដ្ឋជាភាគីទើបយកជាការបាននោះ អ្នកដែលជាប់ជាសមាជិកគណៈកម្មាធិការ គឺបេក្ខជនណាដែលទទួលសំឡេងច្រើនជាងគេបំផុត និងដែលបានសំឡេងភាគច្រើនដាច់ខាតនៃសំឡេង

ឆ្នោតរបស់អ្នកតំណាងរដ្ឋជាភាគី ដែលបានមករួមប្រជុំ ហើយដែលបានបោះឆ្នោត ។

**៥.** សមាជិកនៃគណៈកម្មាធិការត្រូវបានបោះឆ្នោតជ្រើសតាំងសំរាប់៤ឆ្នាំ ។ ប៉ុន្តែអាណត្តិរបស់សមាជិក៩នាក់ ដែលបានជាប់ឆ្នោតក្នុងពេលបោះឆ្នោតលើកទីមួយនោះ នឹងត្រូវចប់តែក្នុងរយៈពេល ២ឆ្នាំប៉ុណ្ណោះ ។ ក្រោយពីការបោះឆ្នោតលើកទីមួយបានចប់សព្វគ្រប់ភ្លាមឈ្មោះរបស់សមាជិកទាំង៩នាក់នេះ នឹងត្រូវប្រធានគណៈកម្មាធិការជ្រើសរើសតាមការចាប់ឆ្នោត ។

**៦.** ការបោះឆ្នោតជ្រើសតាំងសមាជិកគណៈកម្មាធិការ៥នាក់បន្ថែមនោះ នឹងត្រូវធ្វើឡើងអនុលោមតាមបញ្ញត្តិច្បាប់ដែលមានចែងនៅក្នុងកថាខ័ណ្ឌ២ ៣ និង៤នៃមាត្រានេះ បន្ទាប់ពីមានការឲ្យសច្ចាប័នឬការចូលរួមទី៣២ហើយ។ អាណត្តិនៃសមាជិកពីរនាក់ក្នុងចំណោមសមាជិក៥នាក់បន្ថែមនេះ នឹងត្រូវចប់ក្នុងរយៈពេលពីរឆ្នាំ។ ឈ្មោះសមាជិកទាំងពីរនាក់នេះ នឹងត្រូវប្រធានគណៈកម្មាធិការចាប់ឆ្នោតរើស ។

**៧.** ដើម្បីបំពេញកន្លែងទំនេរជាយថាហេតុ រដ្ឋជាភាគីណាដែលមានអ្នកឯកទេសរបស់ខ្លួនឈប់បំពេញការងារក្នុងឋានៈជាសមាជិកគណៈកម្មាធិការហើយនោះ នឹងចាត់តាំងអ្នកឯកទេសម្នាក់ទៀត ក្នុងចំណោមពលរដ្ឋខ្លួន ក្នុងល័ក្ខខ័ណ្ឌដែលមានការយល់ព្រមពីគណៈកម្មាធិការផង។

**៨.** ដោយមានការយល់ព្រមពីមហាសន្និបាត សមាជិកនៃគណៈកម្មាធិការនឹងទទួលបៀវត្សពីថវិការបស់អង្គការសហប្រជាជាតិ ក្នុងក័រិតនិងលក្ខណៈដែលមហាសន្និបាតបានសំរេច ដោយយោងទៅលើសារសំ

ខាន់នៃការទទួលខុសត្រូវរបស់គណៈកម្មាធិការ ។

៩. អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ និងផ្តល់បុគ្គលិក និងសំភារៈចាំបាច់នានា ដើម្បីឲ្យគណៈកម្មាធិការបំពេញការងាររបស់ខ្លួន ដោយប្រសិទ្ធិភាពតាមលំនាំអនុសញ្ញានេះ ។

## មាត្រា១៨

១. រដ្ឋជាភាគីទាំងឡាយមានភារៈដាក់ជូនអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ដើម្បីឲ្យគណៈកម្មាធិការពិនិត្យនូវរបាយការណ៍ស្តីពីវិធានការផ្នែកច្បាប់ ផ្នែកតុលាការ ផ្នែករដ្ឋបាល និងវិធានការផ្សេងៗទៀត ដើម្បីធ្វើឲ្យមានប្រសិទ្ធិភាពដល់បញ្ញត្តិច្បាប់នានានៃអនុសញ្ញានេះ ហើយនិងស្តីពីការរីកចំរើននៅក្នុងវិស័យនេះ ÷

(ក) ក្នុងរវាងពេល១ឆ្នាំក្រោយពីអនុសញ្ញាចូលជាធរមានចំពោះរដ្ឋដែលមានការទាក់ទិន,

(ខ) បន្ទាប់ពីនោះមក យ៉ាងហោចណាស់ក៏រៀងរាល់៤ឆ្នាំម្តង ហើយនិងនៅពេលណាដែលគណៈកម្មាធិការមានសំណើឡើង ។

២. របាយការណ៍អាចលើកឡើងពីកត្តា និងឧបសគ្គទាំងឡាយដែលប៉ះពាល់ដល់កំរិតបំពេញកាតព្វកិច្ច ដែលមានចែងនៅក្នុងអនុសញ្ញានេះ ។

## មាត្រា១៩

១. គណៈកម្មាធិការនឹងអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួនផ្ទាល់។

២. គណៈកម្មាធិការនឹងបោះឆ្នោតជ្រើសរើសបុគ្គលិកការិយាល័យរបស់ខ្លួនសំរាប់អាណត្តិពេលពីរឆ្នាំ ។

## មាត្រា២០

១. គណៈកម្មាធិការនឹងជួបប្រជុំគ្នាជាប្រក្រតីក្នុងរយៈពេលមិនលើសពីពីរអាទិត្យក្នុងមួយឆ្នាំ ដើម្បីពិនិត្យរបាយការណ៍ ដែលទទួលបានតាមការអនុលោមតាមមាត្រា១៨នៃអនុសញ្ញានេះ ។

២. សម័យប្រជុំនឹងត្រូវធ្វើឡើងជាធម្មតា នៅទីស្នាក់ការអង្គការសហប្រជាជាតិ ឬនៅកន្លែងសមស្របណាមួយទៀត តាមការកំណត់របស់គណៈកម្មាធិការ ។

## មាត្រា ២១

១. តាមរយៈក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គម គណៈកម្មាធិការនឹងធ្វើរបាយការណ៍ប្រចាំឆ្នាំជូនមហាសន្និបាតនៃអង្គការសហប្រជាជាតិស្តីពីសកម្មភាពទាំងឡាយរបស់ខ្លួន ហើយនឹងអាចលើកឡើងជាសំណើនិងសេចក្តីផ្តាំផ្ញើរួមបាន ដោយឈរលើមូលដ្ឋាននៃការពិនិត្យរបាយការណ៍ និងពត៌មាននានាដែលទទួលបានពីរដ្ឋជាភាគីទាំងឡាយ។ រាល់សំណើ និងសេចក្តីផ្តាំផ្ញើរួមទាំងនេះ នឹងត្រូវបញ្ចូលទៅក្នុងរបាយការណ៍

របស់គណៈកម្មាធិការ ហើយបើសិនជាមាន ដោយភ្ជាប់ជាមួយនូវសេចក្តីអធិប្បាយរបស់រដ្ឋជាភាគីផង ។

**ខ.** អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ នឹងបញ្ជូលរបាយការណ៍ទាំងឡាយរបស់គណៈកម្មាធិការ ទៅជូនគណៈកម្មការស្តីពីស្ថានភាពរបស់នារីភេទដើម្បីជាពត៌មាន ។

## មាត្រា ២២

អង្គការឯកទេសទាំងឡាយមានសិទ្ធិបញ្ជូនអ្នកតំណាងខ្លួនទៅចូលរួមក្នុងការពិនិត្យលើការអនុវត្តន៍បទបញ្ញត្តិនានានៃអនុសញ្ញានេះ ដែលស្ថិតនៅក្នុងក្របខ័ណ្ឌនៃសកម្មភាពរបស់ខ្លួន។ គណៈកម្មាធិការអាចនឹងស្នើដល់អង្គការឯកទេសទាំងឡាយ ឲ្យបញ្ជូនទៅឲ្យខ្លួននូវរបាយការណ៍ស្តីអំពីការអនុវត្តន៍អនុសញ្ញានេះ ខាងវិស័យទាំងឡាយដែលស្ថិតនៅក្នុងក្របខ័ណ្ឌនៃសកម្មភាពរបស់ខ្លួន ។

## ភាគ ៦

## មាត្រា ២៣

អ្វីៗដែលមាននៅក្នុងអនុសញ្ញានេះ នឹងមិនប៉ះពាល់ដល់បទបញ្ញត្តិទាំងឡាយណា ដែលនាំឲ្យកាន់តែសំរេចបាននូវសមភាពរវាងបុរស និងនារី ដែលអាចមាន ៖

(ក) នៅក្នុងបញ្ញត្តិច្បាប់របស់រដ្ឋជាភាគី; ឬ

(ខ) នៅក្នុងអនុសញ្ញាអន្តរជាតិ សន្ធិសញ្ញា ឬកិច្ចព្រមព្រៀងផ្សេងទៀត ដែលមានជាធរមានចំពោះរដ្ឋនោះ។

## មាត្រា ២៤

រដ្ឋជាភាគីទាំងឡាយមានភារៈត្រូវចាត់វិធានការចាំបាច់ទាំងអស់នៅពាសពេញប្រទេស ដើម្បីធ្វើឲ្យបានសំរេចទាំងស្រុងនូវសិទ្ធិទាំងឡាយដែលត្រូវបានទទួលស្គាល់នៅក្នុងអនុសញ្ញានេះ ។

## មាត្រា ២៥

១. អនុសញ្ញានេះបានបើកចំហជូនរដ្ឋទាំងអស់ចុះហត្ថលេខា ។

២. អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ត្រូវបានចាត់តាំងជាអ្នកទទួលតំកល់ទុកអនុសញ្ញានេះ ។

៣. អនុសញ្ញានេះត្រូវទទួលការឲ្យសច្ចាប័ន។ ឯកសារនៃការឲ្យសច្ចាប័ននេះ នឹងត្រូវដំកល់ទុកនៅនឹងអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ។

៤. សន្ធិសញ្ញានេះនឹងបើកឲ្យមានការចូលរួមពីគ្រប់រដ្ឋទាំងអស់។ ការចូលរួមអាចនឹងសម្រេចទៅបានតាមរយៈការតំកល់ឯកសារសុំចូលរួមនៅនឹងអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ។

## មាត្រា២៦

១. សំណើសុំសើរើអនុសញ្ញានេះ អាចធ្វើបាននៅគ្រប់ពេលវេលា ដោយរដ្ឋជាភាគីណាមួយក៏បាន អាស្រ័យការជូនដំណឹងជាលាយល័ក្ខអក្សរដល់អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ។

២. បើមានសំណើបែបនេះ មហាសន្និបាតនៃអង្គការសហប្រជាជាតិ នឹងកំណត់ពីជំហានដែលត្រូវប្រកាន់យក ។

## មាត្រា ២៧

១. អនុសញ្ញានេះនឹងចូលជាធរមានសាមសិបថ្ងៃក្រោយពីឯកសារឲ្យសច្ចាប័ន ឬសូមចូលរួមទីម្ភៃ ត្រូវបានដំកល់ទុកនៅនឹងអគ្គលេខាធិការនៃអង្គការសហប្រជាជាតិនោះមក ។

២. ចំពោះរដ្ឋនិមួយៗដែលបានឲ្យសច្ចាប័ន ឬដែលបានចូលរួមក្នុងសន្និសញ្ញានេះ ក្រោយពីឯកសារនៃការឲ្យសច្ចាប័ន ឬការចូលរួមទីម្ភៃត្រូវបានដំកល់ទុកហើយនោះ អនុសញ្ញានេះនឹងចូលជាធរមានចំពោះរដ្ឋនោះនៅសាមសិបថ្ងៃក្រោយពីថ្ងៃដែលរដ្ឋនោះបានដំកល់ទុកឯកសារឲ្យសច្ចាប័ន ឬការចូលរួមរបស់ខ្លួនហើយ ។

## មាត្រា ២៨

១. អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ទទួល និងចែកជូនដល់គ្រប់រដ្ឋទាំងអស់នូវអត្ថបទនៃការដាក់ល័ក្ខខ័ណ្ឌរបស់រដ្ឋនានា ដែល

បានធ្វើឡើងនៅពេលឲ្យសច្ចាប័ន ឬនៅពេលសុំចូលរួមនោះ ។

**២.** ការដាក់ល័ក្ខខ័ណ្ឌណាមួយដែលផ្ទុយទៅនឹងកម្មវត្ថុ ហើយនឹងគោលដៅនៃអនុសញ្ញានេះ មិនត្រូវបានអនុញ្ញាតឡើយ ។

**៣.** ការដាក់ល័ក្ខខ័ណ្ឌនេះអាចដកចេញបាន នៅគ្រប់ពេញវេលា ដោយជូនដំណឹងជាលាយល័ក្ខអក្សរស្តីពីបញ្ហានេះដល់អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ដែល(បន្ទាប់មក)នឹងជូនដំណឹងដល់រដ្ឋឯទៀតៗ ។ ការជូនដំណឹងជាលាយល័ក្ខអក្សរនេះ នឹងមានប្រសិទ្ធិភាពនៅថ្ងៃដែលបានទទួល ។

## មាត្រា ២៩

**១.** វិវាទទាំងឡាយរវាងរដ្ឋ(ជាភាគី)ពីរ ឬក៏ច្រើនទៀត ដែលទាក់ទងទៅលើការបកស្រាយ ឬការអនុវត្តន៍អនុសញ្ញានេះ ហើយដែលមិនអាចដោះស្រាយបានតាមរយៈការចរចាទេនោះ អាចដាក់ឲ្យមានការសំរេចអំពីអាជ្ញាកណ្តាលមួយ បើមានសេចក្តីស្នើពីសំណាក់រដ្ឋណាមួយ ។ ក្នុងអំលុងពេលប្រាំមួយខែ ក្រោយពីថ្ងៃដែលបានទទួលសំណើថាឲ្យមានការសំរេចពីអាជ្ញាកណ្តាលនោះ បើភាគីទាំងឡាយមិនបានស្របមតិគ្នាទៅលើការចាត់តាំងឲ្យមានអាជ្ញាកណ្តាលនោះទេ ភាគីណាមួយក្នុងចំណោមភាគីជាគូក្តីទាំងនោះ អាចលើកយករឿងវិវាទនេះទៅតុលាការអន្តរជាតិ ដោយដាក់ពាក្យបណ្តឹងដែលស្របទៅតាមលក្ខន្តិកៈរបស់តុលាការនោះ។

**២.** នៅពេលចុះហត្ថលេខា ឬផ្តល់សច្ចាប័នលើអនុសញ្ញានេះ ឬ

ពេលសុំចូលរួមក្នុងអនុសញ្ញានេះ រដ្ឋនិមួយៗអាចប្រកាសថា ខ្លួនមិននៅក្រោមចំណុះអំណាចច្បាប់ក្នុងកថាខណ្ឌ ១ នៃមាត្រានេះបាន ។ រដ្ឋជាភាគីឯទៀតនឹងមិនជំពាក់ជំពិនក្នុងអំណាចច្បាប់ ដូចមានចែងក្នុងកថាខណ្ឌ ១ នៃមាត្រានេះ ជាមួយនឹងរដ្ឋទាំងឡាយណាដែលបានដាក់ល័ក្ខខ័ណ្ឌនេះឡើយ ។

៣. រដ្ឋជាភាគីទាំងឡាយណាដែលបានដាក់ល័ក្ខខ័ណ្ឌដូចមានចែងក្នុងកថាខណ្ឌ ២ នៃមាត្រានេះ អាចដកល័ក្ខខ័ណ្ឌខ្លួនវិញនៅពេលណាក៏បាន ដោយការជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ។

## មាត្រា ៣០

អនុសញ្ញាដែលមានអត្ថបទជាភាសាអារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញនេះ មានតម្លៃស្មើគ្នា ហើយនឹងត្រូវដំកល់ទុកនៅនឹងអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ។

ជាបន្ទាល់នៃកិច្ចនេះ ភាគីអ្នកចុះហត្ថលេខាខាងក្រោម ដែលបានទទួលការអនុញ្ញាតយ៉ាងពេញលេញពីរដ្ឋាភិបាលរបស់ខ្លួន បានចុះហត្ថលេខានៅលើអនុសញ្ញានេះ ។

ថតចម្លង
បណ្ណសារដ្ឋានជាតិ